**KINGDOM OF CAMBODIA**
**NATION RELIGION KING**

**MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION**

No.2031 MFA-IC/LC4

The Ministry of Foreign Affairs and International Cooperation presents its compliments to the Embassy of the Socialist Republic of Vietnam in Phnom Penh and has the honour to enclose herewith the Note No. 2030 MFA-IC/LC4, dated 18 August 2016, of the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia addressed to the Ministry of Foreign Affairs of the Socialist Republic of Vietnam.

The Ministry would highly appreciate it if the Embassy could kindly forward the enclosed Ministry's Note to its high destination.

The Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia avails itself of this opportunity to renew to the Embassy the assurances of its highest consideration.

Phnom Penh, 18 August 2016

**Embassy of the Socialist
Republic of Viet Nam
Phnom Penh**

Address : N° 3, **Samdech HUN Sen** Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 214 441, 216 122
Fax : (855) 23 216 144, 216 141
Email : mfaic@mfa.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ 2030 កបទ.សអ/ច្បក៤

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែងគារវកិច្ចជូនចំពោះក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងមានកិត្តិយសសូមទាញការចាប់អារម្មណ៍ចំពោះកំណត់ទូតរបស់ក្រសួងការបរទេសកម្ពុជា ពាក់ព័ន្ធនឹងការរំលោភបំពានរបស់វៀតណាមតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដូចខាងក្រោម៖

I. ការជីកស្រះ និងសំណង់ផ្សេងៗនៅខេត្តរតនគីរី

១. ការជីកស្រះ ៩ កន្លែង

–កំណត់ទូតលេខ ១៣៨០ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៥

–កំណត់ទូតលេខ ១៣៨៨ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៥

–កំណត់ទូតលេខ ១២៨២ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៦

កំណត់ទូតទាំង ០៣ នេះ ស្នើភាគីវៀតណាមលុបស្រះទាំង ០៩ បញ្ឈប់ការសាងសង់សំណង់នានា និងចាត់វិធានការទប់ស្កាត់កុំឲ្យពលរដ្ឋវៀតណាមចូលមកដាំដំណាំ ឬធ្វើសកម្មភាពនានានៅចន្លោះបង្គោលព្រំដែន ៣០-៤០ ខេត្តរតនគីរី រហូតដល់គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ចប់ការខណ្ឌសីមាជាស្ថាពរនៅតំបន់នេះ។

២. ការសង់អគារ និងផ្លូវបេតុងនៅខេត្តរតនគីរី

–កំណត់ទូតលេខ ១៨៤៦ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៦ ស្នើភាគីវៀតណាមបញ្ឈប់ការសាងសង់ជាបន្ទាន់អាគារថ្មមួយទំហំ ១៥ ម៉ែត្រ X ២០ ម៉ែត្រ ចន្លោះបង្គោល ៣០-៤០ ខេត្តរតនគីរី និងធ្វើឲ្យស្ថានភាពបរិស្ថានដូចដើមវិញ រហូតដល់គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ចប់ការខណ្ឌសីមាជាស្ថាពរនៅតំបន់នោះ។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

- កំណត់ទូតលេខ ២១០៥ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១២
- កំណត់ទូតលេខ ២៨៩១ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១២
- លិខិតចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** រដ្ឋមន្ត្រីការបរទេសកម្ពុជា ផ្ញើជូនឯកឧត្តម PHAM BINH MINH ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសវៀតណាម
- កំណត់ទូតលេខ ៣២៦១ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៤

កំណត់ទូត និងលិខិតទាំងនេះ ស្នើភាគីវៀតណាមបញ្ឈប់ការធ្វើផ្លូវបេតុងបណ្តោយ ៤១ គ.ម តាមព្រំដែន ពីចន្លោះបង្គោល ៣០ ដល់ ៤៤ ក្នុងខេត្តរតនគីរី រហូតដល់គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ចប់ការខណ្ឌសីមាជាស្ថាពរនៅតំបន់នេះ។

II.ការធ្វើផ្លូវ និងប៉ុស្តិ៍រដ្ឋបាលនៅតំបន់ដាក់ដាំង-ដាក់ហ៊ួត ខេត្តមណ្ឌលគីរី

- កំណត់ទូតលេខ ២១៤៨ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១១
- កំណត់ទូតលេខ ២៤២០ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១១
- កំណត់ទូតលេខ ១០៥២ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១២
- កំណត់ទូតលេខ ២៣៥៩ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣
- កំណត់ទូតលេខ ៦០៧/២០១៣ សរកហ ចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ស្ថានទូតកម្ពុជានៅទីក្រុងហាណូយ
- កំណត់ទូតលេខ ៥៥/២០១៤ សរកហ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ស្ថានទូតកម្ពុជានៅទីក្រុងហាណូយ
- កំណត់ទូតលេខ ៣៥១/២០១៤ សរកហ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៤ របស់ស្ថានទូតកម្ពុជានៅទីក្រុងហាណូយ
- កំណត់ទូតលេខ ០០៥ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៥

កំណត់ទូតទាំងនេះ ស្នើវៀតណាមបញ្ឈប់ការធ្វើផ្លូវ និងអគាររដ្ឋបាលប៉ុប្រាងជាបន្ទាន់នៅតំបន់ដាក់ដាំង-ដាក់ហ៊ួត ខេត្តមណ្ឌលគីរី រហូតដល់គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ចប់ការខណ្ឌសីមាជាស្ថាពរនៅតំបន់នេះ។

III.ការធ្វើផ្លូវនៅខេត្តស្វាយរៀង

- កំណត់ទូតលេខ ១៥៣៥ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៥
- កំណត់ទូតលេខ ៥៩៥ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៦
- កំណត់ទូតលេខ ១៦៩៣ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៦

កំណត់ទូតទាំង ០៣ នេះ ស្នើវៀតណាមបញ្ឈប់ការធ្វើផ្លូវជាបន្ទាន់នៅចន្លោះបង្គោលព្រំដែនលេខ ១៩៤-២០៣ បង្គោលព្រំដែនលេខ ២១១-២១៣ និងបង្គោលព្រំដែនលេខ ២១៣-២២៧ ក្នុងស្រុកចន្ទ្រា និងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ក្នុងទឹកដីដែលកម្ពុជាគ្រប់គ្រង រហូតដល់គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ចប់ការខណ្ឌសីមាជាស្ថាពរនៅតំបន់នេះ។

IV.ការសាងសង់ប៉ុស្ដិ៍យោធានៅខេត្តកណ្ដាល

–កំណត់ទូតលេខ ១៣១៨ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១៥

–កំណត់ទូតលេខ ១៤១៨ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៥

កំណត់ទូតទាំងពីរនេះ ស្នើភាគីវៀតណាមបញ្ឈប់ជាបន្ទាន់ការសាងសង់ប៉ុស្ដិ៍យោធា នៅភូមិព្រែកស្បូវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល រហូតដល់គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ចប់ការខណ្ឌសីមាជាស្ថាពរនៅតំបន់នេះ។

V.ការធ្វើប៉ុស្ដិ៍នៅច្រកទ្វារវិញហួយដុង ជាប់បង្គោលព្រំដែនលេខ ២៦០ ទល់មុខច្រក ទ្វារទូភាគី កំពង់ក្រសាំង ស្រុកបុរីជលសារ ខេត្តតាកែវ

–កំណត់ទូតលេខ ៩០៤ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៦

–កំណត់ទូតលេខ ១៦៩៣ កបទ-សអ/ច្បក៤ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៦

កំណត់ទូតទាំងពីរនេះ ស្នើវៀតណាមបញ្ឈប់ជាបន្ទាន់ការសង់ប៉ុស្ដិ៍នៅច្រកទ្វារត្រួតពិនិត្យវិញហួយដុងរបស់វៀតណាម នៅជាប់បង្គោលព្រំដែនលេខ ២៦០ ស្រុកបុរីជលសារ និងធ្វើឲ្យស្ថានភាពបរិស្ថាននៅតំបន់នេះមានសភាពដូចដើមវិញ រហូតដល់គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ចប់ការខណ្ឌសីមាជាស្ថាពរនៅតំបន់នេះ។

ស្របតាមស្មារតីនិងខ្លឹមសារនៃកំណត់ទូត និងលិខិតដូចដែលបានជំរាបជូនទាំងអស់ខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាសូមស្នើរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមជាថ្មីម្ដងទៀត សូមឲ្យបញ្ឈប់សកម្មភាពសាងសង់ទាំងអស់ខាងលើជាបន្ទាន់ និងធ្វើឲ្យស្ថានភាពបរិស្ថាននៅតំបន់ដូចរៀបរាប់ខាងលើមានសភាពដូចដើមវិញ ព្រមទាំងចាត់វិធានការរារាំងកុំឲ្យពលរដ្ឋវៀតណាមចូលមកដាំដុះ ឬធ្វើសកម្មភាពនៅតំបន់ព្រំដែនទាំងឡាយណាដែលមិនទាន់បញ្ចប់ការខណ្ឌសីមា និងបោះបង្គោលព្រំដែន ក្នុងស្មារតីមិត្តភាព ភាពជាអ្នកជិតខាងដ៏ល្អ និងទំនាក់ទំនង

ជិតស្និទ្ធជាប្រពៃណី ដោយត្រូវទុកឲ្យគណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបញ្ចប់ការខណ្ឌសីមាឲ្យបានចប់ជាស្ថាពរសិន។

ឆ្លៀតឱកាសនេះផងដែរ យោងតាមលទ្ធផលនៃកិច្ចប្រជុំរវាងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាម កាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៦ នៅទីក្រុងហូជីមិញ ដែលថ្នាក់ដឹកនាំទាំងពីរបានឯកភាពគ្នាស្នើសុំបារាំងផ្តល់អ្នកជំនាញបច្ចេកទេសខាងផែនទី មកចម្លងខ្សែព្រំដែនពីផែនទីបោន ខ្នាត១/១០០ ០០០ ទៅលើផែនទី UTM ខ្នាត ១/៥០ ០០០ នៅចន្លោះបង្គោលព្រំដែនលេខ ៣០-៤០ ស្ថិតក្នុងខេត្តរតនគិរី/ដាក់ឡាក់ និងនៅចន្លោះបង្គោលព្រំដែនលេខ ១៣៨-១៤៧ ស្ថិតក្នុងភូមិជ្ជងខេត្តស្វាយរៀង/តៃនីញ ព្រមទាំងជួយដៅខ្សែព្រំដែននៅលើដីជាក់ស្តែងនោះ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជាសង្ឃឹមថា គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរ ដែលគ្រោងនឹងប្រជុំចង្អៀត នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ នៅភ្នំពេញ នឹងឆាប់ឯកភាពគ្នាលើលិខិតស្នើសុំទៅ**ឯកឧត្តមប្រធានាធិបតីបារាំង** ដើម្បីពិនិត្យលទ្ធភាពផ្តល់ជំនួយបច្ចេកទេសនេះឲ្យបានឆាប់។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឆ្លៀតក្នុងឱកាសនេះ សូមសំដែងនូវគារវកិច្ចសារជាថ្មីដល់ក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

ភ្នំពេញ ថ្ងៃទី១៨ ខែ សីហា ឆ្នាំ ២០១៦

ក្រសួងការបរទេសនៃសាធារណរដ្ឋ
សង្គមនិយមវៀតណាម
ហាណូយ